# សូមប្រាកដថាកូនរបស់អ្នកនៅតែមានការធានារ៉ាប់រង!

## ការសុំបន្តជំនួយ Medicaid ជាថ្មីនឹងមកដល់។

**សូមឪពុកម្ដាយយកចិត្តទុកដាក់!** តើកូនរបស់អ្នកត្រូវបានធានារ៉ាប់រងតាមរយៈ KanCare ដែរឬទេ? ការផ្លាស់ប្ដូរកំពុងកើតឡើងចំពោះ Medicaid។ ការផ្លាស់ប្ដូរទាំងនេះអាចប៉ះពាល់ដល់ការរ៉ាប់រងសម្រាប់មនុស្សជាទីស្រលាញ់របស់អ្នក។ ប្រសិនបើអ្នក ឬកូនរបស់អ្នកបច្ចុប្បន្នបានចុះឈ្មោះក្នុង Medicaid អ្នកប្រហែលជាត្រូវបន្តការធានារ៉ាប់រងរបស់អ្នក។ ដំណើរការបន្តគឺមានសារៈសំខាន់ដើម្បីជួយកូនរបស់អ្នកឱ្យរក្សាការធានារ៉ាប់រងសុខភាពរបស់ពួកគេ។

### ✓ ជំហានទី 1៖ ធ្វើបច្ចុប្បន្នភាពព័ត៌មានសម្រាប់ទំនាក់ទំនងរបស់អ្នក

ត្រូវប្រាកដថា KanCare មាន **ព័ត៌មានទាក់ទងថ្មីចុងក្រោយ** បំផុតរបស់អ្នក។ ក្នុងនេះគឺមានរួម អាសយដ្ឋានផ្ញើសំបុត្រ អ៊ីមែល និង លេខទូរសព្ទរបស់អ្នក។ សូមធ្វើបច្ចុប្បន្នភាពព័ត៌មាននេះ ដោយហៅទូរស័ព្ទទៅលេខ 800-792-4884 ឬប្រើ chatbot នៅលើគេហទំព័រ KanCare.ks.gov

SCAN ME

kancare.ks.gov

### ✓ ជំហានទី 2៖ ឆែកប្រអប់សំបុត្ររបស់អ្នកឱ្យបានញឹកញាប់

អ្នកនឹងទទួលបានលិខិតដែលបានបោះពុម្ពមួយដែលពន្យល់អ្នក ឬសិទ្ធិទទួលបានរបស់កូនអ្នកសម្រាប់ Medicaid។ លិខិតនេះនឹងប្រាប់អ្នក **ពីរបៀបបន្តការធានារ៉ាប់រងរបស់អ្នក** ។

### ✓ ជំហានទី 3៖ បំពេញទម្រង់បែបបទបន្តជាថ្មីរបស់អ្នកនៅកាលបរិច្ឆេទកំណត់

បំពេញទម្រង់បែបបទបន្តជាថ្មី ហើយបញ្ជូនទម្រង់នោះទៅ KanCare តាមអាសយដ្ឋានដែលបានផ្ដល់ឱ្យ។ មានកាលបរិច្ឆេទ និងពេលវេលាជាក់លាក់ដែលទម្រង់បែបបទនេះត្រូវបំពេញ។ វាជាការប្រសើរក្នុងការផ្ញើទម្រង់បែបបទនេះដែលមានហត្ថលេខា ទោះជាអ្នកមិនមានព័ត៌មានពេញលេញភ្លាមៗក៏ដោយ ជាជាងរង់ចាំព័ត៌មានទាំងអស់។

ប្រសិនបើអ្នកមិនប្រគល់ទម្រង់បែបបទស្នើសុំបន្តជំនួយជាថ្មី ឲ្យបានទាន់ពេលកំណត់ទេនោះ **គ្រួសាររបស់អ្នកអាចបាត់បង់ការធានារ៉ាប់រងសុខភាព** ដោយមិនគិតថា អ្នកមាន ឬមិនមានសិទ្ធិទទួលបានជំនួយឡើយ។ ដើម្បីអាចដឹងថាតើខែណា ដែលអ្នកត្រូវសុំបន្តជំនួយជាថ្មី សូមទូរសព្ទទៅ KanCare Clearinghouse (800-792-4884) ឬអ្នកផ្ដល់សេវាធានារ៉ាប់រងរបស់អ្នក។



## លែងមានសិទ្ធិទទួលបានជំនួយទៀតហើយមែនទេ? សូមទាក់ទងទៅអ្នកសម្របសម្រួលសេវាសម្រាប់ជំនួយដោយឥតគិតថ្លៃ។

**www.getcoveredkansas.org**

Cover Kansas™

*ការបោះពុម្ពផ្សាយនេះ ត្រូវបានគាំទ្រដោយមជ្ឈមណ្ឌលសម្រាប់សេវា Medicare និង Medicaid (Centers for Medicare and Medicaid Services (CMS)) របស់ ក្រសួងសុខាភិបាល និងសេវាពលរដ្ឋនៃសហរដ្ឋអាមេរិក (U.S. Department of Health and Human Services (HHS)) ជាផ្នែកមួយនៃការផ្ដល់ជំនួយផ្នែកហិរញ្ញវត្ថុ ដែលទទួលបានមូលនិធិ 100 ភាគរយពី CMS/HHS។ មាតិកាទាំងនេះគឺជាមាតិការបស់អ្នកនិពន្ធ ហើយមិនចាំបាច់សុទ្ធតែតំណាងឱ្យទស្សនៈផ្លូវការរបស់អ្នកនិពន្ធ ឬគាំទ្រដោយ CMS/HHS ឬរដ្ឋាភិបាល U.S. នោះឡើយ។*

# សូមប្រាកដថាកូនរបស់អ្នកនៅតែមានការធានារ៉ាប់រង!

## ការសុំបន្តជំនួយ Medicaid ជាថ្មីនឹងមកដល់។

**សូមឪពុកម្ដាយយកចិត្តទុកដាក់!** តើកូនរបស់អ្នកត្រូវបានធានារ៉ាប់រងតាមរយៈ KanCare ដែរឬទេ? ការផ្លាស់ប្ដូរកំពុងកើតឡើងចំពោះ Medicaid។ ការផ្លាស់ប្ដូរទាំងនេះអាចប៉ះពាល់ដល់ការរ៉ាប់រងសម្រាប់មនុស្សជាទីស្រលាញ់របស់អ្នក។ ប្រសិនបើអ្នក ឬកូនរបស់អ្នកបច្ចុប្បន្នបានចុះឈ្មោះក្នុង Medicaid អ្នកប្រហែលជាត្រូវបន្តការធានារ៉ាប់រងរបស់អ្នក។ ដំណើរការបន្តគឺមានសារៈសំខាន់ដើម្បីជួយកូនរបស់អ្នកឱ្យរក្សាការធានារ៉ាប់រងសុខភាពរបស់ពួកគេ។